# ព្រះរាជាណាចក្រកម្ពុជា
## ជាតិ សាសនា ព្រះមហាក្សត្រ

*********

# កិច្ចព្រមព្រៀង
## រវាង
## សិប្បកម្មប៉ាក់ ខុនហ្វីខែន អ៊ីមប្រ៉យឌឺរី ជាមួយ
## ប្រតិភូបុគ្គលិក និងតំណាងកម្មករនិយោជិត

នៅថ្ងៃទី.២៨ខែ.ធ្នូ.ឆ្នាំ២០២២ វេលាម៉ោង.៩ព្រឹក.និង...៣០.នាទី នៅក្នុង

**បរិវេនារោងចក្រ**

មានកិច្ចប្រជុំមួយរវាងតំណាងរោងចក្រ ប៉ាក់ ខុនហ្វីខែន អ៊ីមប្រ៉យឌឺរី នឹងតំណាងកម្មករ និយោជិក។

នៅក្នុងអង្គប្រជុំនេះ នាយករោងចក្របានជូនដំណឹងដល់កម្មករនិយោជិតទាំងអស់ស្ដីពីស្ថានភាពបច្ចុប្បន្នក្រុមហ៊ុនខ្វះការបញ្ជាទិញ ដែលបណ្ដាលអោយច្រវ៉ាក់ផលិតកម្មត្រូវផ្អាកដំណើរការ។ ហេតុដូចនេះក្រុមហ៊ុនសម្រេចចិត្តព្យួរកិច្ចសន្យាការងាររបស់កម្មករនិយោជិតចំនួន ១៧នាក់ (ស្រី ៨នាក់) ក្នុងចំណោមកម្មករនិយោជិតសរុប ២០ (ស្រី ១៣នាក់) (ក្នុងប្រព័ន្ធព្យួរកិច្ចសន្យាការងារ កម្មករនិយោជិតមានចំនួន ២៩នាក់ (ស្រី ១៧នាក់) ហើយក្នុងចំណោមកម្មករនិយោជិត ២៩នាក់ កម្មករនិយោជិតដែលបានលាឈប់ពី ក្រុមហ៊ុនចំនួន ១២នាក់ (ស្រី ៩នាក់) ) រយៈពេល៦០ថ្ងៃ ដោយគិតចាប់ពីថ្ងៃទី ១ ខែមករា ឆ្នាំ២០២៣ រហូតដល់ថ្ងៃទី ១ ខែមិនា ឆ្នាំ២០២៣។ ហើយក្នុងកំឡុងពេលព្យួរការងារនេះ កម្មករនិយោជិកបានឯកភាពទទួលការផ្ដល់ជូនរបស់រោងចក្រនូវប្រាក់ឈ្នួល ២៥%នៃប្រាក់ឈ្នួលប្រចាំថ្ងៃ ដោយរាប់បញ្ចូលប្រាក់ថ្លៃធ្វើដំណើរ៧ដុល្លានៅក្នុងហ្នឹងតែម្ដង។

ប្រាក់ឧបត្ថម្ភក្នុងកំឡុងពេលព្យួរកិច្ចសន្យាការងានេះ និងបើកជូនបងប្អូនកម្មករ នៅថ្ងៃទី ១ ខែ មករា ឆ្នាំ ២០២៣។

អង្គប្រជុំបានចប់នៅវេលាម៉ោង..១០..និង៣០..នាទី ព្រឹកនាថ្ងៃខែឆ្នាំដដែល ប្រកបដោយបរិយាកាសរីករាយ និងស្និតស្នាលក្រោមស្មារតីទទួលខុសត្រូវខ្ពស់ និងយោបល់សហការគ្នាយ៉ាងរលូន។

ថ្ងៃពុធ ៦កើត ខែបុស្ស ឆ្នាំខាល ចត្វាស័ក ពុទ្ធសករាជ ២៥៦៦

រាជធានី ភ្នំពេញ ថ្ងៃទី២៨ ខែធ្នូ ឆ្នាំ២០២២

**តំណាងរោងចក្រ**

**ស្នាមមេដៃតំណាងកម្មករ និយោជិក**